**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ធំ និង នាយកវិទ្យាល័យ **ខ្នៀវិល** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ប្រកាសលេខ ៤០០ អយក. ប្រក
## ស្តីពីការប្តូរឈ្មោះ «អនុវិទ្យាល័យ កោះចូរ៉ាម »ទៅជា
## អនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម
## ស្ថិតនៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ-ច្បាបលេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យកោះចូរ៉ាមលេខ ០៤/៩៦ អនុវិ.កចរ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា អភិបាលខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យកោះចូរ៉ាមទៅជា «**អនុវិទ្យាល័យ ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម**» ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុ - វិទ្យាល័យ **ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ៦-ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៤៦៤ សករ.**

**ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងការ**

**បញ្ជូនពលករខ្មែរទៅធ្វើការនៅកោះតៃវ៉ាន់**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា